# របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម

**កម្មវិធីរបស់ The Asian International Justice Initiative**

ឆ្នាំទី១ លេខ ១៩ សប្តាហ៍ទី១៩ (៣១ សីហា ‐ ០២ កញ្ញា ឆ្នាំ២០០៩)


## "សវនាការអង្គសេចក្តីលើករណីអតីតប្រធានមន្ទីរ ស-២១ កាំង ហ្គិចអាវ ហៅ ឌុច"



*រូបភាព : លោក កាំង ហ្គិចអ៊ាវ ហៅ ឌុច ក្នុងបន្ទប់សវនាការ (អតីតប្រធានមន្ទីរ ស-២១)*

## ១. សេចក្តីផ្តើម

*"ខ្ញុំសោកស្តាយចំពោះគាត់ដែលជាមនុស្សមានគុណធម៌ បែរក្លាយជាជនឧក្រិដ្ឋទៅវិញ"*[១]

*"ខ្ញុំអំពាវនាវដល់មនុស្សគ្រប់រូប សូមផ្តល់ឱកាសឱ្យខ្ញុំក្លាយជាជនសាមញ្ញម្តងទៀត"*[២]

ដូចបានគ្រោងទុក ការពិភាក្សាដេញដោលលើសក្ខីកម្មសាក្សីពាក់ព័ន្ធអត្តចរិកជនជាប់ចោទត្រូវបានចាប់ផ្តើម នាសប្តាហ៍នេះ ។ ដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សី រួមមាន សាក្សីជំនាញខាងផ្នែកចិត្តសាស្ត្រចំនួន ២រូប និងមិត្តភ័ក្រ្ត ព្រមទាំងអតីតមិត្តរួមការងារជនជាប់ចោទចំនួន ៤រូប ។ សាក្សីជំនាញខាងផ្នែកចិត្តសាស្ត្របានពន្យល់ពីការវិភាគរបស់ពួកគេលើការវាយតម្លៃ **ឌុច** គឺសិក្សាវាយតម្លៃលើ *"ភូមិសាស្ត្រនយោបាយ"* ដោយពិចារណាពីបរិបទសង្គម និងនយោបាយ ដែលឧក្រិដ្ឋកម្មបានប្រព្រឹត្ត ។ តាមរយៈនេះ សាក្សីជំនាញរកឃើញថា ជនជាប់ចោទមានឥរិយាបទម៉ឺងម៉ាត់នឹងការងារ គឺដើម្បីអាយុជីវិតខ្លួន និងក្រុមគ្រួសារ ។ ទន្ទឹមនឹងនោះ ស្ថានភាពផ្លូវចិត្តរបស់ជនជាប់ចោទមានភាពខុសប្លែក នៅពេលគាត់ជួបប្រទះបញ្ហាផ្សេងៗក្នុងជីវិត ។ សាក្សីជំនាញក៏បានពន្យល់ពីមូលហេតុដែល **ឌុច** អាចក្លាយជាមេគ្រួសារដ៏ល្អម្នាក់ កំឡុងពលគាត់ជាប្រធានមន្ទីរសន្តិសុខ ដែលមនុស្សរាប់ពាន់ត្រូវធ្វើទារុណកម្ម និងសម្លាប់ ។ ក្រៅពីចំណុចនេះ សាក្សីជំនាញបានបញ្ជាក់ថា ជនជាប់ចោទមិនមានវិបត្តិផ្លូវចិត្តទេ ហើយមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមនីតិវិធីសវនាការ ។

---

[១] ការពន្យល់របស់លោក **ទេព សុខ** ពីការលើកឡើងថា បុរសម្នាក់ដែលលោកស្គាល់ គឺ ហង់ ពិន ឥឡូវកាយជាអតីតប្រធានមន្ទីរ ស-២១ កាលពីថ្ងៃទី២ កញ្ញា ២០០៩

[២] ការថ្លែងរបស់ជនជាប់ចោទនៅថ្ងៃទី០២ កញ្ញា ២០០៩

## ២. បញ្ហាច្បាប់ និងនីតិវិធី

### ក. សេចក្តីសង្ខេបសក្ខីកម្មអំពីអត្តចរិកជនជាប់ចោទ

នាសប្តាហ៍នេះ ទាំងអង្គជំនុំជម្រះ និងភាគី លើកលែងតែដើមបណ្តឹងរដ្ឋប្បវេណី បានសួរដេញដោលសាក្សី ដែលសក្ខីកម្មសង្ខេបរួមមានខាងក្រោម :

**១. ការផ្តល់សក្ខីកម្មរួមគ្នារបស់សាក្សីជំនាញលោក ការ ស៊ុនបូណាត និងលោកស្រី Francoise Silboni-Guilbaud**

នៅថ្ងៃច័ន្ទ និងព្រឹកថ្ងៃអង្គារ សាក្សីជំនាញផ្នែកចិត្តសាស្ត្រលោក **ការ ស៊ុនបូណាត** និងលោកស្រី Francoise Silboni-Guilbaud បានរួមគ្នាមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ។ សក្ខីកម្មនេះឆ្លើយតបនឹងសំណួរជាក់លាក់មួយចំនួន ដែលពាក់ព័ន្ធអត្តចរិកជនជាប់ចោទ ។

***បញ្ហាសុខភាព និងផ្លូវចិត្ត :*** សាក្សីជំនាញលើកឡើងនូវគំនិតតែមួយថា **ឌុច** មិនមានការឈឺចាប់ និងបញ្ហាផ្លូវចិត្តទេ ។ ការសន្និដ្ឋានរបស់ពួកគេបានបញ្ជាក់យ៉ាងច្បាស់ថា **ឌុច** ពិតជាមានឆន្ទៈទទួលខុសត្រូវចំពោះការងារខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

***ការទទួលរងបញ្ហាផ្លូវចិត្តពីសកម្មភាពនៅមន្ទីរ ស-២១ :*** សក្ខីកម្មសាក្សីជំនាញ គឺមានសារៈសំខាន់ក្នុងការបំភ្លឺថា **ឌុច** មានការរំជួលចិត្តចំពោះសកម្មភាពនៅមន្ទីរ ស-២១ ។ សក្ខីកម្មនេះហាក់ពន្យល់ពីទស្សនៈវិស័យមួយខុសប្លែកពីសក្ខីកម្មជនជាប់ចោទ ។

***ការទទួលស្គាល់ទំនួលខុសត្រូវ :*** សាក្សីជំនាញបានឱ្យដឹងថា **ឌុច** ពិតជាមិនមានចេតនាប្រព្រឹត្តកំហុសទេ (តាមទស្សនៈបស្ចឹមប្រទេស) ។ សំខាន់ជាងនេះ សាក្សីជំនាញបានលើកឡើងដដែលៗថា **ឌុច** ស្ថិតក្នុងស្ថានភាពដឹកនាំ និងគ្រប់គ្រងមន្ទីរ ស-២១ ដោយការរំជួលចិត្ត និងភាពភ័យខ្លាច ។ **ឌុច** មិនបដិសេធនូវអារម្មណ៍ផ្លូវចិត្តដ៏ធ្ងន់ធ្ងររបស់ជនរងគ្រោះទេ ហើយថែមទាំងបង្ហាញពីវិប្បដិសារីរបស់ខ្លួនចំពោះប្រជាជនខ្មែរទៀត ។ សាក្សីជំនាញអះអាងថា ការលើកឡើងពីវិប្បដិសារី និងការជួសជុលជំងឺចិត្ត គឺជនជាប់ចោទធ្វើដោយពិតប្រាកដ និងឥតក្លែងបន្លំ ។ បន្ថែមលើនេះ ជនជាប់ចោទថែមទាំងជួយសម្រួលដល់កិច្ចនីតិវិធីទៀតផង ។

**២.សាក្សីផ្តល់សក្ខីកម្មអំពីអត្តចរិកជនជាប់ចោទ**

តាមកាលវិភាគ សាក្សី ៦រូប បានចូលខ្លួនផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃអង្គារ និងថ្ងៃពុធ រួមមាន អតីតមិត្តរួមថ្នាក់ ១រូប អតីតសិស្ស ២រូប និងមិត្តរួមការងារ ៣រូប ដែលបានលើកឡើងពីទំនាក់ទំនង និងអត្តចរិករបស់ជនជាប់ចោទ ។ សក្ខីកម្មសាក្សីមានពីរប្រភេទ ទី១-សាក្សីស្គាល់ជនជាប់ចោទមុនឆ្នាំ១៩៦៨ ទី២-សាក្សីស្គាល់ជនជាប់ចោទក្នុងនាម **ហង់ ពិន** ក្រោយរបបខ្មែរក្រហម ។ សាក្សីទាំងនោះរួមមាន :

- លោកស្រី **ស៊ូ សាត** អតីតមិត្តរួមថ្នាក់ នៅខេត្តកំពុងធំ ថ្នាក់ទី ៣ និងទី៤ សង្គមចាស់ (១៩៥៩-១៩៦១)
- លោក **ទេព សែម** អតីតសិស្ស នៅសាលាជើងព្រៃ ខេត្តកំពុងចាម (១៩៦៥-១៩៦៨)
- លោក **ទេព សុខ** អតីតសិស្ស នៅសាលាជើងព្រៃ ខេត្តកំពុងចាម ដំបូងអះអាងថា រៀនជាមួយជនជាប់ចោទនៅឆ្នាំ ១៩៦៨-១៩៦៩ ក្រោយមកអះអាងថា ប្រហែលជានៅឆ្នាំ ១៩៦៦-១៩៦៦៧

- លោក **ជូ វិន** អតីតចៅហ្វាយនាយ និងជាមិត្តរួមការងារនៅមន្ទីរអប់រំស្រុកស្វាយចេក (១៩៩៥-១៩៩៧)

- លោក **ហ៊ុន ស្មៀន** អតីតនាយក និង មិត្តរួមការងារនៅវិទ្យាល័យស្វាយចេក (១៩៩៦-១៩៩៧)

- លោក **ប៉េង ភ័ណ** អតីតអ្នកគ្រប់គ្រង នៅវិទ្យាល័យភូគាំ (១៩៩៣-១៩៩៥)

បន្ទាប់ពីសក្ខីកម្មសាក្សី **ប៉េង ភ័ណ** ត្រូវបញ្ចប់ ជនជាប់ចោទមានឱកាសផ្តល់នូវការអង្កេតលើសក្ខីកម្មរបស់សាក្សី ប៉ុន្តែគាត់មិនមានការជំទាស់ណាមួយលើសក្ខីកម្មទាំងនោះទេ ។

## សាក្សីស្គាល់ជនជាប់ចោទមុនជាប់ពន្ធនាគារសម័យ លន់ ណុល

***ទំនាក់ទំនងជាមួយជនជាប់ចោទ :*** សាក្សី **ស៊ូ សាត**, **ទេព សែម** និង **ទេព សុខ** ផ្តល់សក្ខីកម្មនៅថ្ងៃអង្គារ ។ អ្នកស្រី **ស៊ូ សាត** មានអាយុ ៦៦ឆ្នាំ ជាគ្រូបង្រៀនចូលនិវត្តន៍ និងជាមិត្តរួមថ្នាក់ជនជាប់ចោទ ។ សាក្សី **ទេព សែម** អះអាងថា គាត់ជាកូនសិស្ស **ឌុច** ប្រហែលជា ៣ឆ្នាំ ។ រីឯសាក្សី **ទេព សុខ** ក៏អះអាងថា គាត់ក៏ជាសិស្ស **ឌុច** នៅកំឡុងឆ្នាំ១៩៦៨-១៩៦៩ ប៉ុន្តែនៅពេលសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីលើកឡើងថា **ឌុច** ជាប់ពន្ធនាគារនៅឆ្នាំ១៩៦៨-១៩៧0 សាក្សីបង្វែរថា គាត់ច្រលំកាលបរិច្ឆេទ ប្រហែលជាឆ្នាំ១៩៦៧-១៩៦៨ ។ អតីតសិស្សទាំងពីររបស់ **ឌុច** ក៏ធ្វើការជាគ្រូបង្រៀនមុនពេលចូលនិវត្តន៍ ។ **ទេព សែម** រៀបរាប់ថា គាត់ជ្រើសអាជីពនេះដោយសារគំរូជនជាប់ចោទ ។

***អត្តចរិកជនជាប់ចោទ :*** សាក្សីទាំងបីរូបពិពណ៌នាថា **ឌុច** ជាមនុស្សចិត្តល្អ មានឆន្ទៈចែករំលែកចំណេះដឹងដល់អ្នកដទៃ គាត់ជាមនុស្សសុភាពរាបសារមិនធ្លាប់មានជម្លោះ ឬប្រព្រឹត្តហិង្សាណាមួយឡើយ ។ អ្នកស្រី **ស៊ូ សាត** កត់សម្គាល់ថា **ឌុច** មិនមានមិត្តភ័ក្តិច្រើនដូចគេទេ នេះដោយសារចរិកធម្មជាតិរបស់គាត់ ។ សាក្សីបន្ថែមថា ជនជាប់ចោទជា*"មនុស្សស្លូតត្រង់ និងស្ងៀមស្ងាត់"* ។ ចំណែកឯអតីតសិស្សទាំងពីរលើកឡើងថា គ្រូរបស់គេជាមនុស្សស្មើភាពនិយម និងរាប់រកសិស្សគ្រប់គ្នា ។ ពួកគេមិនធ្លាប់ឮនរណារិះគន់គ្រូខ្លួនឡើយនៅសាលាជើងព្រៃ ។

***ការបង្ហាញពីគំនិតនយោបាយ :*** អ្នកស្រី **ស៊ូ សាត** មិនអាចផ្តល់ព័ត៌មានពីមូលហេតុ ដែលជនជាប់ចោទចូលរួមបក្សកុម្មុយនីស្តបានឡើយ ។ **ទេព សែម** រំឭកថា **ឌុច** ធ្លាប់ធ្វើការកត់សម្គាល់ពីភាពខុសគ្នារវាងវណ្ណៈនៅសង្គមកម្ពុជា ដែលជារឿយៗនៅចុងម៉ោងសិក្សា ។ ជនជាប់ចោទបានបង្ហាញពីទស្សនៈមនោគមន៍វិជ្ជា *"គំនិតកុម្មុយនីស្ត"* ប៉ុន្តែមិនធ្លាប់បញ្ចុះបញ្ចូលសិស្សឱ្យចូលរួមចលនាបដិវត្តន៍ទេ ។

## សាក្សីស្គាល់ជនជាប់ចោទកំឡុងឆ្នាំ១៩៧៩-១៩៩៩

សក្ខីកម្មសាក្សី **ជូ វិន**, **ហ៊ុន ស្មៀន** និង **ប៉េង ភ័ណ** បានបង្ហាញពីសកម្មភាព និងអត្តចរិកជនជាប់ចោទបន្ទាប់ពីសម័យខ្មែរក្រហម ។ សាក្សីស្គាល់ជនជាប់ចោទក្នុងនាម **ហង់ ពិន** មិនមែនឈ្មោះ **កាំង ហ្គិចអ៊ាវ** ហៅ **ឌុច** នោះទេ។ សាក្សីបានអះអាងថាពួកគេមិនធ្លាប់ដឹងពីមុខងារជនជាប់ចោទ នៅសម័យកម្ពុជាប្រជាធិបតេយ្យទេ ទើបតែដឹងនៅថ្ងៃចាប់ខ្លួនក្នុងឆ្នាំ១៩៩៩ ។

***ទំនាក់ទំនងជាមួយជនជាប់ចោទ :*** លោក **ជូ វិន** គឺជាសាក្សីដំបូងស្គាល់ជនជាប់ចោទនៅឆ្នាំ១៩៩៥-១៩៩៧ នៅពេលនោះគាត់គឺជាអនុប្រធានមន្ទីរអប់រំស្រុកស្វាយចេក ។ សាក្សីទទួលជនជាប់ចោទឱ្យធ្វើជាជំនួយការ និងអនុញ្ញាតឱ្យស្នាក់នៅការិយាល័យថែមទៀត ដោយបារម្ភពីសន្តិសុខ បន្ទាប់ពីជនជាប់ចោទត្រូវចោរប្លន់ ។ ក្នុងអំពើប្លន់នោះបណ្តាលឱ្យប្រពន្ធគាត់ត្រូវស្លាប់ ។

***អត្តចរិកជនជាប់ចោទ :*** សាក្សីរំឮកថា ជនជាប់ចោទជាមនុស្សប្រកបដោយសមត្ថភាពខ្ពស់ ។ **ជូ វិន** លើកឡើងថា ជនជាប់ចោទជាជំនួយការដ៏ល្អ មានសមត្ថភាព និងជាមនុស្សទៀងទាត់ពេលវេលា ។ សាក្សីពិពណ៌នាថា ក្នុងឋានៈគាត់ជាគ្រូបង្រៀនជនជាប់ចោទជាមនុស្សដាក់ខ្លួន និងយកចិត្តទុកដាក់ក្នុងការងារ ។ ក្រៅពីខិតខំធ្វើការងារ ជនជាប់ចោទជាមនុស្សទៀតទាត់ និងមានការរៀបចំខ្ពស់ ជាមនុស្សសុភាពរាបសារ និងស្ងប់ស្ងាត់ ទាំងគ្រូទាំងសិស្សគោរពកោតសរសើរ និងដាក់រហ័សនាមគាត់ថា *"គ្រូតា"* ។

***អំពើប្លន់នៅឆ្នាំ ១៩៩៥ :*** អំពើប្លន់នៅឆ្នាំ ១៩៩៥ ធ្វើឱ្យភរិយាគាត់ត្រូវបាត់បង់ជីវិត សាក្សីបានអះអាងថា ពួកគាត់មិនបានដឹងច្បាស់ពីឧប្បទ្ទវហេតុនោះទេ ។ ទោះបីជា សាក្សី **ប៉េង ភ័ណ** ជួយជនជាប់ចោទកំឡុងពេលនោះ ក៏គាត់នូវតែដឹងតិចតួចពីបញ្ហានោះ ។ សាក្សីបានរៀបរាប់ថា ជនជាប់ចោទមានរបួស ហើយគាត់ជាអ្នកបញ្ជូនជនជាប់ចោទទៅព្យាបាលនៅមន្ទីរពេទ្យ ។ បន្ទាប់ពីជនជាប់ចោទចេញពីមន្ទីរពេទ្យ គាត់បានផ្តល់ការណែនាំមួយចំនួនពីវិធីបញ្ចៀសគ្រោះថ្នាក់ ដូច្នេះទើប **ឌុច** ទៅរស់នៅមន្ទីរអប់រំស្រុកស្វាយចេក ។ សាក្សី ២រូប លើកឡើងថា ករណីនេះហាក់ពាក់ព័ន្ធបញ្ហានយោបាយ តែទោះយ៉ាងណា សាក្សី **ប៉េង ភ័ណ** មិនអាចបញ្ជាក់បានទេលើចំណុចនេះ ។ សាក្សីគ្រប់រូបលើកឡើងថា កំឡុងពេលនោះ បញ្ហាសន្តិសុខ អស្ថេរភាព និងបទល្មើសកើតឡើងជាញឹកញាប់ ប៉ុន្តែអំពើប្លន់កម្រលបណ្តាលឱ្យមានការបាត់បង់ជីវិតណាស់ ។

***ការសម្របខ្លួនក្នុងសង្គមក្រោយរបបខ្មែរក្រហម :*** លោក **ជូ វិន** បានអះអាងថា លោកចាប់ផ្តើមស្គាល់ **ឌុច** ក្នុងបរិបទនយោបាយមួយ ខណៈដែលការប្រយុទ្ធគ្នាបន្តកើតមានរវាងភាគីតស៊ូនានា និងអតីតរដ្ឋកម្ពុជា ។ ទោះបីជាយ៉ាងណា ដោយសារតែតំបន់ស្វាយចេកមិនគ្រប់គ្រងដោយខ្មែរក្រហម នៅពេលនោះ **ឌុច** មានលទ្ធភាពសម្របខ្លួនបានយ៉ាងងាយក្នុងសហគមន៍ តែមិនលាតត្រដាងអំពីអត្តសញ្ញាណខ្លួន ។ សាក្សី ២រូបទៀត បានបញ្ជាក់ពីមនោសញ្ចេតនានេះ ដោយថ្លែងអះអាងនូវអ្វីដែលបានដឹងថាជនជាប់ចោទមិនដែលមានទំនាស់ជាមួយអ្នករួមការងារ ឬសមាជិកក្នុងសហគមន៍ឡើយ ។ លោក **ប៉េង ភ័ណ** បានគូសបញ្ជាក់នូវហេតុការណ៍នោះថា ក្នុងឋានៈជាគ្រូបង្រៀននៅវិទ្យាល័យពូគាំអស់រយៈកាល ២ឆ្នាំ **ឌុច** បម្រើការងារដោយស្ម័គ្រចិត្ត និងមិនទទួលកម្រៃឧបត្ថម្ភឡើយ ។ ទោះបីជាយ៉ាងណា បញ្ហានេះមិនប៉ះពាល់ដល់ការបំពេញការងារជាគ្រូបង្រៀនរបស់គាត់ទេ ។

### ៣. លោក កាំង ហ្គិចអ៊ាវ ហៅ ឌុច

នៅថ្ងៃពុធ អង្គជំនុំជម្រះបានបន្តការសួរដេញដោលលើ **ឌុច** ជាថ្មីម្តងទៀតអង្គជំនុំជម្រះបានផ្អាកកិច្ចដំណើរការនីតិវិធីដោយតុលាការត្រូវសម្រាករយៈពេល ១សប្តាហ៍ ដើម្បីរៀបចំកិច្ចប្រជុំពេញអង្គ ។ តាមគោលការណ៍សន្មត់ជាមុនថា *"គ្មានទោស"* លោកស្រីចៅក្រម **Cartwright** និងលោកចៅក្រម **Lavergne** បានបំភ្លឺដល់ **ឌុច** ដោយយកចិត្តទុកដាក់ថា ទោះបីជាអង្គហេតុ

នានាពាក់ព័ន្ធអត្តចរិកជនជាប់ចោទនឹងបញ្ចូលជាធាតុផ្សំក្នុងការដាក់ទោស ក៏**ឌុច**មិនទាន់ជាប់ពិរុទ្ធភាពនៅឡើយ ។ ការសួរដេញដោលក្នុងពេលនេះអាចមានសារៈសំខាន់ ល្គឹះណាជនជាប់ចោទមានពិរុទ្ធប៉ុណ្ណោះ ។

***ការងារ ឌុច នៅមន្ទីរ ស-២១ :*** នៅពេលលោកស្រីចៅក្រម **Cartwright** ទាញចំណាប់អារម្មណ៍ **ឌុច** ចំពោះយោបល់សាក្សីថា **ឌុច** បានធ្វើអ្វីៗលើសពីតម្រូវការចាំបាច់ដើម្បីរស់រានមានជីវិតនៅមន្ទីរ ស-២១ ។ **ឌុច** បានចង្អុលបង្ហាញថា គាត់មិនមានបទដ្ឋានអាចកំណត់ ថាតើការងារនោះទទួលបានឬទេ? សម័យខ្មែរក្រហម គឺជារបបសាហាវយង់ឃ្នង់ ឃោរឃៅ និងឆ្កួតលីលា ដែលមើលឃើញមនុស្សគ្រប់រូបថាជាជនក្បត់ ។ លើសពីនេះទៀត ភាពភ័យខ្លាចរបស់គាត់ គឺជាការពិត ព្រោះគាត់មិនមានលទ្ធភាពបំពេញការងារទាំងអស់ទេ បើទោះជាប្រឹងប្រែងយ៉ាងណាក៏ដោយ ។

***ការទទួលស្គាល់ទំនួលខុសត្រូវ :*** **ឌុច** បានសារភាពថា គាត់ដឹងថា ការពិឃាដមនុស្សដោយមិនមានមូលហេតុ គឺជាឧក្រិដ្ឋកម្មមួយដ៏ធ្ងន់ធ្ងរ ។ តែទោះជាយ៉ាងណា គាត់ជឿជាក់ថា គាត់គឺជាអ្នកទោសម្នាក់ ដែលអនុវត្តតាមបទបញ្ជាមេ ។ **ឌុច** ក៏បានផ្តល់សក្ខីកម្មយ៉ាងលម្អិតនូវការប៉ុនប៉ងចាក់ចេញពីតួនាទីខ្លួនដែរ ។

លោកស្រីចៅក្រម **Cartwright** និងលោកចៅក្រម **Lavergne** បានគូសបញ្ជាក់ពីភាពមិនស៊ីសង្វាក់គ្នារវាងកេរ្តិ៍ឈ្មោះរបស់ **ឌុច** ដែលជាគ្រូបង្រៀនមានការលះបង់ និងប្តេជ្ញាចិត្តខ្ពស់ ព្រមទាំងការអនុវត្តន៍របស់គាត់តាមគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដែលមិនឱ្យតម្លៃដល់ការអប់រំ និងបំពាក់បំប៉ន់ក្មេងៗក្នុងន័យឱ្យប្រព្រឹត្តអំពើឃោរឃៅ ។ តាមការឆ្លើយតបរបស់ **ឌុច** ថា គាត់មានភាពស្ទាក់ស្ទើរ និងគ្មានជម្រើសទេ ។ ទោះបី **ឌុច** ជំទាស់នឹងការប្រើអំពើហិង្សា និងការពិឃាដមនុស្សក៏គាត់មានអារម្មណ៍ថា បក្សកុម្មុយនីស្តបានបង្ខំឱ្យគាត់ទទួលយល់គោលនយោបាយនោះ ដើម្បីភាពត្រឹមត្រូវផ្នែកនយោបាយ ។

## ៣. ការចូលរួមរបស់ជនរងគ្រោះ និងសាក្សី និងការការពារ និងកិច្ចគាំពារជនរងគ្រោះ

***វត្តមានភាគីដើមបណ្តឹងរដ្ឋប្បវេណី :*** ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនបានចូលរួមកិច្ចដំណើរការនីតិវិធីទេនាសប្តាហ៍នេះ ព្រោះតវ៉ាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ កាលពីថ្ងៃទី២៧ ខែសីហា ២០០៩ ដែលកម្រិតពីសិទ្ធិចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី (សូមមើលផ្នែក *"ការតវ៉ារបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី"* ខាងក្រោម) ។

***វត្តមានមេធាវីតំណាង :*** មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ និងក្រុម៤ បានអវត្តមានពេញមួយសប្តាហ៍ ។ នាថ្ងៃចុងក្រោយនៃកិច្ចដំណើរការនីតិវិធី ការជូនដំណឹងមួយបានឱ្យដឹងថា ពួកគេអវត្តមានដោយសារជាប់រវល់ស្រាវជ្រាវរកភស្តុតាងបន្ថែមទៀត ដើម្បីគាំទ្រពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីកូនក្តីរបស់ខ្លួន ។

នៅថ្ងៃច័ន្ទ អង្គជំនុំជម្រះក៏បានទទួលស្គាល់មេធាវីតំណាងអន្តរជាតិថ្មី ១រូប សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ គឺលោកស្រី **Martino** ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិក្រុម១ កញ្ញា **ទី ស្រីណា** បានធ្វើបទឧទ្ទេសនាមបង្ហាញលោកស្រី **Martino** ដើម្បីឱ្យអង្គជំនុំជម្រះទទួលស្គាល់ ខណៈមេធាវីជាតិក្រុម៣ អវត្តមាននាថ្ងៃនោះ ។

***ដើមបណ្តឹងរដ្ឋប្បវេណីធ្វើពហិការមិនចូលរួមសវនាការ :*** ការធ្វើពហិការរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងគោលបំណងបង្ហាញដល់សាធារណៈជននូវការជំទាស់ដាច់អហ័ង្ការចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលកម្រិតសិទ្ធិមេធាវីតំណាងមិនឱ្យសួរដេញដោលជនជាប់ចោទ និងសាក្សីនានាពាក់ព័ន្ធអត្តចរិកជនជាប់ចោទ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសន្និសីទសារព័ត៌មានមួយកាលពីថ្ងៃច័ន្ទ នៅមុខបរិវេណតុលាការ លោក **ជុំ ស៊ីរ៉ាត** និង **ជុំ មុី** បានបញ្ជាក់នូវការទាមទាររបស់ខ្លួនក្នុងឋានៈជា *ភាគីទទួលស្គាល់ពេញសិទ្ធិ* ដោយវិធានផ្ទៃក្នុង ។ ពួកគេបានធ្វើលិខិតបើកមួយជូនអង្គជំនុំជម្រះសុំឱ្យទទួលស្គាល់សិទ្ធិរបស់ពួកគេដូចភាគីដទៃក្នុងកិច្ចនីតិវិធី ។ ដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់បន្ថែមថា សកម្មភាពនេះគឺបង្ហាញពីឆន្ទៈផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនជះឥទ្ធិពលដល់មេធាវីតំណាងទេ ។ ខណៈនោះមេធាវីតំណាងនៅតែបន្តវត្តមានក្នុងកិច្ចដំណើរការនីតិវិធី ។

## ៤. ការគ្រប់គ្រងសវនាការ

***ការគ្រប់គ្រងផ្នែកតុលាការ :*** សក្ខីកម្មជនជាប់ចោទត្រូវបានកាត់ផ្តាច់ជាច្រើនលើកគួរជាក្តីបារម្ភ ។ ទោះបីជា **ឌុច** បានចាប់ផ្តើមផ្តល់សក្ខីកម្មអំពីអត្តចរិករបស់ខ្លួនកាលពីថ្ងៃព្រហស្បតិ៍ ក៏ការណ៍នេះនៅតែត្រូវបានបង្អាក់ ដើម្បីសម្រួលដល់ការស្តាប់សក្ខីកម្មអ្នកជំនាញផ្នែកចិត្តសាស្ត្រ ២រូប ដែលបានគ្រោងទុក ។ សក្ខីកម្មរបស់ **ឌុច** នឹងចាប់ផ្តើមបន្តនៅពេលសក្ខីកម្មសាក្សីបញ្ចប់មុនការកំណត់ ។ គួរកត់សម្គាល់ បញ្ហានេះបានកើតឡើងម្តងហើយ ចំពោះសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី **ជុំ នៅ** ដែលត្រូវបង្អាក់ដើម្បីជួយសម្រួលដល់សក្ខីកម្មតាមប្រព័ន្ធវីដេអូពីចម្ងាយ ។ ការធានាឱ្យកិច្ចដំណើរនីតិវិធីបញ្ចប់តាមកាលបរិច្ឆេទ គឺជាក្តីកង្វល់យ៉ាងសំខាន់ ជាពិសេស ចំពោះការបង្អាក់ចរន្តសក្ខីកម្មនេះ ។ ស្ថានភាពទាំងពីរខាងលើ ធ្វើឱ្យមានភាពលំបាកក្នុងការបន្ត ឬតាំងសំណួរតាមលំដាប់ ដូច្នេះករណីនេះគួរធ្វើតែនៅពេលចាំបាច់ ។

***បញ្ហាចោទនៃគោលការណ៍ផ្លាស់ប្តូរសហព្រះរាជអាជ្ញាអន្តរជាតិក្នុងការសួរដេញដោល :*** កម្រិតនៃកិច្ចសហការក្នុងការិយាល័យសហព្រះរាជអាជ្ញាអន្តរជាតិហាក់ដូចជាចោទជាបញ្ហានៅសប្តាហ៍នេះ ខណៈដែលលោក **Vincent de Wilde** បានដាក់សេចក្តីសន្និដ្ឋានកាលពីថ្ងៃអង្គារ មិនបានផ្អែកលើព័ត៌មានច្បាស់លាស់ ។ លោក **Vincent de Wilde** បានលើកឡើងនូវការសង្កេត និងការជំទាស់របស់ខ្លួនចំពោះ សំណើដែលមេធាវីការពារក្តីមិនបានលើកឡើង ។ ការសង្កេតរបស់លោក **Vincent de Wilde** គឺជាការភាន់ច្រឡំ ហើយមិនបានឆ្លើយតបចំពោះសំណើដែលមេធាវីការពារក្តីបានធ្វើឡើយ នេះជាបញ្ហាចោទចំពោះកម្រិតព័ត៌មានដែលទទួលបានពីសហសេវិករបស់គាត់ នៅពេលមានវត្តមានក្នុងបន្ទប់សវនាការ ។ មេធាវីការពារក្តីអន្តរជាតិលោក **Roux** បានជំទាស់នឹងសេចក្តីសន្និដ្ឋានលោក **de Wilde** ថា *"ទទួលព័ត៌មានមិនជិតដល់ និងមិនគ្រប់គ្រាន់"* នូវអង្គហេតុដែលបានលើកឡើង ។

***កាលវិភាគ :*** នៅថ្ងៃច័ន្ទ អង្គជំនុំជម្រះបានលើកឡើងនូវកាលវិភាគសវនាការ ពីការកំណត់បញ្ចប់សវនាការសួរដេញដោល គឺត្រឹមថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ ។ ការសួរដេញដោលលើប្រធានបទចុងក្រោយពាក់ព័ន្ធអត្តចរិកជនជាប់ចោទនឹងធ្វើឡើងនៅថ្ងៃប្រហស្បតិ៍ ទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ។ ប្រសិនបើការសួរដេញដោលនេះមិនបញ្ចប់ នឹងបន្តធ្វើនៅសប្តាហ៍បន្ទាប់ និងភាគីអាចដាក់ឯកសារបន្ថែមចំពោះមុខអង្គជំនុំជម្រះ ប្រសិនបើមាន ។

អង្គជំនុំជម្រះបានសម្រេចកំណត់ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់របស់ភាគី នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ទោះជាយ៉ាងណា សហព្រះរាជអាជ្ញាបានដាក់សំណើសុំពន្យាពេលទៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ វិញ ។ ទាំងមេធាវីការពារក្តី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពុំមានការជំទាស់លើបញ្ហានេះទេ តែស្នើថា ការសម្រេចរបស់អង្គជំនុំជម្រះលើករណីនេះគួរជូនដំណឹងដល់ភាគីមុនតាមដែលអាចធ្វើបាន ដើម្បីឱ្យពួកគេមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រៀមលក្ខណៈជាមុន ។

| **កាលបរិច្ឆេទ** | **កាលវិភាគការផ្តល់សក្ខីកម្មសាក្សី និងជនជាប់ចោទ** |
|---|---|
| ថ្ងៃច័ន្ទ ទី៣១ សីហា ២០០៩ | លោក ការ ស៊ុនបូណាត និងលោកស្រី **Francoise Silboni-Guilbaud** (សាក្សីជំនាញ) |
| ថ្ងៃអង្គារ ទី០១ កញ្ញា ២០០៩ | លោកស្រី ស៊ូ សាត លោក ទេព សែម លោក ទេព សុខ និង លោក ជូ វិន (ផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងអត្តចរិកជនជាប់ចោទ) |
| ថ្ងៃពុធ ទី០២ កញ្ញា ២០០៩ | លោក ហ៊ុន ស្មៀន លោក ប៉េង ភ័ណ (ផ្តល់សក្ខីកម្មពាក់ព័ន្ធអត្តចរិកជនជាប់ចោទ) |
| ថ្ងៃច័ន្ទ-អង្គារ ទី១៤-១៥ កញ្ញា ២០០៩ | លោក **Richard Goldstone** (ផ្តល់សក្ខីកម្មតាមប្រព័ន្ធឆ្លើយឆ្លងវិដេអូពីចម្ងាយ) លោក **Christopher Lapel** លោក **Stephane Hessel** សាក្សី **D8** និងលោក**Raoul Marc Jennar** |
| ថ្ងៃពុធ-ប្រហស្បតិ៍ ទី១៦-១៧ កញ្ញា ២០០៩ | ការសួរដេញដោលជនជាប់ចោទ កាំង ហ្គិចអ៊ាវ ហៅ ឌុច |
| ថ្ងៃអង្គារ-ពុធ ទី២២-២៣ កញ្ញា ២០០៩ | កាលបរិច្ឆេទនេះបម្រុងទុកសម្រាប់ការផ្តល់សក្ខីកម្មជនជាប់ចោទ ប្រសិនបើចាំបាច់ និងភាគីអាចដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះ ។ |

***ការតែងតាំងសហព្រះរាជអាជ្ញាស្តីទី :*** លោក **William Smith** ត្រូវបានតែងតាំងជាសហព្រះរាជអាជ្ញាស្តីទី ចាប់ផ្តើមពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៩ នេះតទៅ ។ ការតែងតាំងនេះ គឺចន្លោះពេលដែលសហព្រះរាជអាជ្ញា **Robert Petit** លាលែងពីតំណែង និងរហូតសហព្រះរាជអាជ្ញាថ្មីឡើងកាន់តំណែង ។

***វត្តមានរបស់ភាគី :*** លោក **តាន់ សេណារុង** តំណាងសហព្រះរាជអាជ្ញាជាតិពេញមួយសប្តាហ៍ ចំណែកលោក **Anees Ahmed** តំណាងសហព្រះរាជអាជ្ញាអន្តរជាតិនៅថ្ងៃច័ន្ទ និងព្រឹកថ្ងៃអង្គារ ដើម្បីបញ្ចប់ការសួរដេញដោលលើសាក្សីជំនាញអំពីអត្តចរិកជនជាប់ចោទ ។ នៅរសៀលថ្ងៃអង្គារ និងព្រឹកថ្ងៃពុធ លោក **Vincent de Wilde** មានវត្តមាន និងរសៀលថ្ងៃពុធ លោក **William Smith** មានវត្តមានជំនួស ។ ចំណែកឯមេធាវីការពារក្តីលោក **ការ សាវុត្ថ** និងលោក **Francois Roux** មានវត្តមានពេញមួយសប្តាហ៍ ។

***វត្តមានសាធារណៈជន :*** សូមថ្លែងអំណរគុណដល់ អ.វ.ត.ក ក្នុងការរៀបចំប្រជាពលរដ្ឋចូលរួមសវនាការនាសប្តាហ៍នេះ ។ នៅថ្ងៃច័ន្ទ ប្រជាពលរដ្ឋប្រមាណជា ២០០នាក់ មកពីខេត្តពោធិ៍សាត់ និង ២០០នាក់ទៀត មកពីខេត្តកណ្តាល ។ នៅថ្ងៃអង្គារ ប្រជាពលរដ្ឋប្រមាណជា ៣៥០នាក់ មកពីខេត្តតាកែវ និងខេត្តកណ្តាល ព្រមទាំងបុគ្គលិកហ្វឹកហ្វឺនការងារ ២៧នាក់ មកពីអង្គការ the Swedish International Development Agency ។ នៅថ្ងៃពុធ ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងក្តីលេខ០០២ ប្រមាណជា ៥០នាក់ បានចូលរួមសវនាការក្រោមការរៀបចំពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងប្រជាពលរដ្ឋខ្មែរ-ឥស្លាម ប្រមាណជា ៣៥០នាក់ មកពីខេត្តកំពុងចាម ។

## តារាងគ្រប់គ្រងពេលវេលា

| ថ្ងៃ- កាលបរិច្ឆេទ | ចាប់ផ្តើម | សំរាក- ព្រឹក | សម្រាក អាហារថ្ងៃត្រង់ | សម្រាក ពេលរសៀល | ម៉ោងបញ្ចប់ | សរុបចំនួនម៉ោង |
|---|---|---|---|---|---|---|
| ចន្ទ័ ៣១-០៨-០៩ | ០៩:០៥ | ១០:៣០-១០:៥៥ | ១២:១០-១៣:៣០ | ១៥:០០-១៥:២០ | ១៦:១៥ | ៥ ម៉ ០៥ នាទី |
| អង្គារ ០១-០៩-០៩ | ០៩:០០ | ១០:១០-១០:៣៥ | ១២:១០-១៣:៣២ | ១៤:៤០-១៥:០៥ | ១៦:១៥ | ៥ ម៉ ០៦ នាទី |
| ពុធ ០២-០៩-០៩ | ០៩:០៥ | ១០:៤៥-១១:០៥ | ១២:០៥- ១៣:៣៣ | ១៤:៤៥- ១៥:០៥ | ១៦:២០ | ៥ ម៉ ០៧ នាទី |
| ព្រហស្បត្តិ៍ ០៣-០៩-០៩ | - | - | - | - | - | - |

ចំនួនម៉ោងជាមធ្យម : ៥ ម៉ ០៦ នាទី

ចំនួនម៉ោងសរុបនាសប្តាហ៍នេះ : ១៥ ម៉ ១៨ នាទី

ចំនួនសរុប ម៉ោង ថ្ងៃ និង សប្តាហ៍ នៅសវនាការ : ៣០៤ ម៉ ១២ នាទី នៃ ៦៨ ថ្ងៃសវនាការ នៃសប្តាហ៍ទី ១៩

---

**អំពីកម្មវិធីអ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម** (“កម្មវិធី”) : ជាកម្មវិធីរបស់អង្គការ the Asian International Justice Initiative (AIJI) ដែលជាកិច្ចសហការណ៍រវាង U.C. Berkeley War Crimes Studies Center និង East-West Center ។

កម្មវិធីនេះចេញរបាយការណ៍ប្រចាំសប្តាហ៍ អំពីកិច្ចដំណើរការនីតិវិធីសវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បច្ចុប្បន្ន កម្មវិធីនេះកំពុងតែឃ្លាំមើលដំណើរការនៃការកាត់ទោសលើសំណុំរឿង **កាំង ហ្គិចអ៊ាវ** ហៅ **ឌុច** ដែលជារឿងក្តីដំបូងឈានដល់ដំណាក់កាលជំនុំជម្រះ ។

របាយការណ៍ប្រចាំសប្តាហ៍នេះ ត្រូវបានរៀបចំដោយក្រុមឃ្លាំមើលតុលាការ ដែលដឹកនាំដោយលោកស្រី **Michelle Staggs** ជានាយិការងនៃអង្គការ AIJI ដែលមានសមាសភាពដូចខាងក្រោម :

**ក្រុមទី១**
- លោកស្រី **ជូ វិនាថ** : ប្រធានកម្មវិធីសង្កេតការណ៍តុលាការនៃ CSD
- លោក **ង៉ែត សុវណ្ណនិត** : បុគ្គលិកអង្គការ KID
- កញ្ញា **Yvette Anthony** : សិង្ហបុរី
- លោក **Florian Hansen** : អាល្លឺម៉ង់
- កញ្ញា **Caroline Ehlert Zurich** : ស្វីស
- កញ្ញា **Deepika Sharma** : សហរដ្ឋអាមេរិក

**ក្រុមទី២**
- កញ្ញា **សេក សុវណ្ណា** : មេធាវី អង្គការ CLEC
- លោក **ភ័ក្រ្ត សាវ៉ន** : បុគ្គលិកអង្គការ UNOHCHR
- កញ្ញា **Aviva Nababan** : ឥណ្ឌូនេស៊ី
- កញ្ញា **Dephia Lim** : សិង្ហបូរី
- កញ្ញា **Binxin Zhang** : ចិន
- លោក **Jaspreet Dosanjh** : សហរដ្ឋអាមេរិក

កម្មវិធីនេះ បានសហការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) និង (KID) ដើម្បីផ្សព្វផ្សាយរបាយការណ៍នេះ ។ លោក-អ្នកអាចរកបាននូវរបាយការណ៍នេះជាភាសាខ្មែរ និងអង់គ្លេស នៅក្នុង www.csdcambodia.org ; www.kidcambodia.org និង http://Socrates.berkeley.edu/-warcrime/ ។